ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៧៤/២១.....អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី «វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តសៀមរាប» ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម រីវ៉ន ឃុន ប្រធានក្រុមប្រឹក្សាខេត្ត**
- **លោកស្រី ឌិម សុគន្ធា មេឃុំព្រៃជ្រូក ស្រុកពួក**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍មូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្តីផ្តើម

ថ្នាក់ដឹកនាំខេត្តសៀមរាប មានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្ត មានជីវភាពធូធារតាមរយៈកិច្ចការសំខាន់ៗ ដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការដឹកនាំ ការអនុវត្តតួនាទី ភារកិច្ច ស្របតាមជំនាញ និងបទពិសោធន៍ ការផ្លាស់ប្តូរទស្សនៈ ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្រោមឱវាទ ដែលឈានទៅរកការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍប្រកបដោយដោយសមធម៌ និងចីរភាព។

### II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលក្រុមប្រឹក្សាសម្រេចបានរួមមាន៖

❖ ក្រុមប្រឹក្សាខេត្ត

- ក្រុមប្រឹក្សាខេត្តសៀមរាបមានសមាសភាពសរុបចំនួន ២៧រូប ស្រី ០៣រូប ដែលមកពីគណបក្សនយោបាយចំនួន ០២ គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ២៦អាសនៈ និងគណបក្សខ្មែររួបរួមជាតិទទួលបាន ០១អាសនៈ។ ក្រុមប្រឹក្សាក្រុង ស្រុកក្នុងខេត្តសៀមរាប មានចំនួនសរុបចំនួន ២១៦នាក់ ស្រី ៣៦នាក់ និងក្រុមប្រឹក្សាឃុំ សង្កាត់ សរុបចំនួន ៦៦៨ នាក់ ស្រី ១៤៣នាក់។
- ក្រុមប្រឹក្សាខេត្តអាណត្តិទី៣ បានចេញដីកា និងសេចក្តីសម្រេច ចំនួន ១៣ ក្នុងនោះ មានដីកាបទបញ្ជាផ្ទៃក្នុង ចំនួន ០១ និងសេចក្តីសម្រេច ចំនួន ១២។ ក្រៅពីនេះក៏បានអនុម័តលើប្រតិទិនកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តទៅតាមឆ្នាំនីមួយៗ បានចំនួន ០២ ហើយបានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ២០លើក វិសាមញ្ញចំនួន ០២លើក និងសម្ងាត់ចំនួន ០៣លើក។ ដោយឡែក ក្នុងឆ្នាំ២០២០ បានអនុវត្ត និង បំពេញតួនាទី ភារកិច្ចរបស់ខ្លួនដោយបានរៀបចំកិច្ចប្រជុំសាមញ្ញ ១២លើក កិច្ចប្រជុំវិសាមញ្ញចំនួន ០១លើក (កិច្ចប្រជុំសម្ងាត់បានចំនួន ១លើក)។
- ក្រុមប្រឹក្សាខេត្តបានដាក់ចេញនូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍនៅក្នុងអាណត្តិទី៣ ដោយបង្កើនប្រសិទ្ធភាព គុណភាព និងតម្លាភាព នៃការផ្តល់សេវាសាធារណៈក្នុងខេត្ត ជំរុញ និងកែលម្អនូវសេវាកម្ម និងផលិតផលនានា ដែលបម្រើឱ្យវិស័យទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក៏ដូចជាលើកកម្ពស់នូវសោភ័ណ្ឌភាព ក្នុងខេត្តឱ្យស្របតាមសក្តានុពលទេសចរណ៍ ដែលខេត្តមានការយកចិត្តទុកដាក់លើកកម្ពស់ជីវភាព និងសុខមាលភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និងសម្បត្តិវប្បធម៌ប្រពៃណីជាតិដែលមានក្នុងខេត្ត។ ដើម្បីសម្រេចបាននូវចក្ខុវិស័យសម្រាប់ការអភិវឌ្ឍនៅក្នុងអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត រដ្ឋបាលខេត្តមានគោលបំណងអភិវឌ្ឍន៍ចម្បងៗចំនួន ៤ផ្នែក រួមមាន ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ផ្នែកគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។
- ក្រោយពីក្រុមប្រឹក្សាខេត្ត បានអនុម័តក្របខណ្ឌអភិវឌ្ឍខេត្ត ផែនការអភិវឌ្ឍប្រាំឆ្នាំ និងផែនការវិនិយោគបីឆ្នាំរំកិល ដែលមានសំណើគម្រោងពីគ្រប់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខេត្ត មន្ទីរ-អង្គភាពជុំវិញខេត្ត ហើយក្នុងនោះ គម្រោងវិនិយោគរបស់រដ្ឋបាលខេត្តសៀមរាប សម្រាប់អនុវត្តក្នុងឆ្នាំ២០២០ សរុបចំនួន ១៩៧គម្រោង ក្នុងនោះគម្រោងមានការសន្យាគាំទ្រដោយរដ្ឋបាលខេត្តសរុបចំនួន ៥២គម្រោង និងគម្រោងមានការគាំទ្រតាមបណ្តាមន្ទីរ-អង្គភាពសរុប ចំនួន ១៤៥គម្រោង។

- ការដោះស្រាយលើសំណួរ សំណូមពរដែលបានទទួលពីវេទិកាផ្សព្វផ្សាយឆ្នាំ២០១៩ មានចំនួន ៣០៧ ហើយសំណួរ សំណូមពរ បានដោះស្រាយនិងឆ្លើយបំភ្លឺសរុបបាន ចំនួន ២១៧សំណួរ សំណូមពរ នៅសល់ចំនួន ៦៦សំណួរ សំណូមពរដែលបានដាក់យន្តការឱ្យដោះស្រាយ និងកំពុងដំណើរការដោះស្រាយ។
- ក្រុមប្រឹក្សាខេត្តបានបង្កើតក្រុមការងារចុះគាំទ្រ និងចូលរួមការងារសម្របសម្រួលក្នុងកិច្ចប្រជុំ និង ចុះដល់តាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់ និង មន្ទីរ-អង្គភាព ដើម្បីទទួលបានព័ត៌មាន ផ្តល់យោបល់ និងដោះស្រាយបញ្ហាប្រឈម ព្រមទាំងជំរុញការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់និងមន្ទីរ-អង្គភាព បានចំនួន ៤៦៨លើក ។
- លទ្ធផលការងាររបស់គណៈកម្មាធិការ កាតព្វកិច្ចរបស់ក្រុមប្រឹក្សាទាំង ០៣ ទទួលបានដូចខាងក្រោម ៖
  - គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្នុងអាណត្តិទី៣ បានដំណើរការកិច្ចប្រជុំសរុបចំនួន ០៥លើក ដើម្បីពិនិត្យ ពិភាក្សា និងដោះស្រាយសំណួរ សំណូមពរ និងក្តីកង្វល់របស់ប្រជាពលរដ្ឋ ដែលបានលើកឡើងក្នុងវេទិកាផ្សព្វផ្សាយ និង ពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងបញ្ហាផ្សេងៗដែលមន្ទីរ-អង្គភាព និងរដ្ឋបាលក្រុង ស្រុក បានស្នើលើកឡើងជារបៀបវារៈពិនិត្យពិភាក្សា និងដោះស្រាយ។
  - គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) បានដំណើរការកិច្ចប្រជុំចំនួន ១២លើក ក្រៅពីកិច្ចប្រជុំ គ.ក.ស.ក បានចុះដោះស្រាយបញ្ហាប្រឈមនៅមូលដ្ឋាន ដែលពាក់ព័ន្ធនិងស្ត្រី យុវវ័យ កុមារ និងជនងាយរងគ្រោះ។ ជាមួយគ្នានោះ គ.ក.ស.ក ក៏បានរៀបចំប្រជុំផ្សព្វផ្សាយ ស្តីពីការពង្រឹងតួនាទី ភារកិច្ចរបស់ គ.ក.ស.ក ដល់ គ.ក.ស.ក ក្រុង- ស្រុកទាំង ១២ និង គ.ក.ន.ក ឃុំ សង្កាត់ ជារៀងរាល់ឆ្នាំ និងជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងនៅមូលដ្ឋាន។ ក្រៅពីការគាំទ្ររបស់រដ្ឋបាលខេត្ត សកម្មភាពទាំងនេះក៏ទទទួលបានការគាំទ្រពីអង្គការដៃគូរផងដែរ។
  - គណៈកម្មាធិការលទ្ធកម្មបានដំណើរការកិច្ចប្រជុំចំនួន ០៨លើក ដោយប្រើប្រាស់យន្តការតម្លាភាពលើការដេញថ្លៃរបស់ក្រុមហ៊ុនផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្ភារប្រើប្រាស់ និងការអនុវត្តប្រតិបត្តិការចំណាយប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាល។

❖ ឃុំព្រៃជ្រូក នៃស្រុកពួក

ដើម្បីឆ្លើយតបនឹងគោលនយោបាយ កំណែទម្រង់រដ្ឋបាលដ៏ស៊ីជម្រៅ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ រដ្ឋបាលឃុំព្រៃជ្រូកបានខិតខំ បម្រើសេវាជូនប្រជាពលរដ្ឋ សំដៅកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការបង្កើតមុខរបរ ប្រាក់ចំណូល និងរក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន ឃុំព្រៃជ្រូកសម្រេចបាននូវសមិទ្ធផលការងារដូចខាងក្រោម ៖

- ការងារអត្រានុកូលដ្ឋាន ៖ បានខិតខំបម្រើនូវសេវានេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា ព្រមទាំងបានបង្វិត សេវានេះឱ្យកាន់តែជិតប្រជាពលរដ្ឋដូចជា ការបង្កើតយុទ្ធនាការចុះធ្វើសំបុត្រកំណើតជូនប្រជាពលរដ្ឋដែលមក សម្រាលកូននៅមណ្ឌលសុខភាពជាដើម។
    - ចុះបញ្ជីកំណើត បានចំនួន ១៨៩ នាក់
    - ចុះបញ្ជីបញ្ជាក់កំណើត បានចំនួន ៥៧ នាក់
    - ចុះបញ្ជីមរណៈភាព បានចំនួន ៣០ នាក់
    - ចុះបញ្ជីអាពាហ៍ពិពាហ៍ បានចំនួន ៦៦ គូ
- ផ្នែកអត្តសញ្ញាណកម្ម ៖ ផ្តល់សៀវភៅគ្រួសារ (ក៤) ២៣ ក្បាល, ផ្តល់សៀវភៅស្នាក់នៅ (ក២) ២៦ ក្បាល, ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ១០១ សន្លឹក ។
- ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ៖ បានធ្វើការដោះស្រាយ និង សម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ បានចំនួន១០ ករណី
    - គ្រោះទឹកជំនន់៖ កើតមាន ០១លើក បណ្តាលឱ្យលិចផ្ទះប្រជាពលរដ្ឋចំនួន ៤៦ ខ្នងផ្ទះ និងស្រូវចំនួន ៦៧ហិតា ។
    - ការពង្រឹងប៉ុស្តិ៍រដ្ឋបាលដឹកនាំប្រជាការពារ រៀបចំសណ្តាប់ធ្នាប់តាមសួនសាធារណៈ និងការងារបង្ការទប់ស្កាត់ ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន ។
    - រដ្ឋបាលឃុំព្រៃជ្រូកបានរៀបចំប្រជុំ ពិភាក្សាការងារភូមិ ឃុំ មានសុវត្ថិភាព ជាមួយអាជីវករក្នុងឃុំដើម្បីស្វែងរកមូលនិធិគាំទ្រ ប្រជាការពារឃុំ ។
    - ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ឃុំព្រៃជ្រូក ទទួលបានចំណាត់លេខ១ ក្នុងការអនុវត្តគោលនយោបាយនេះ ។
    - កម្លាំងប្រជាការពារសរុបក្នុងឃុំមានចំនួន ៧៣នាក់ ក្នុងនោះឃុំបានឧបត្ថម្ភថវិកាដល់ប្រជា ការពារឃុំ ប្រចាំខែចំនួន ៧៣នាក់ សម្រាប់ឆ្នាំ ២០២០ អស់ថវិកា ២.២០០.០០០៛ (ថវិកាបានមកពីការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ប្រចាំខែ) ព្រមទាំងឧបត្ថម្ភសំលៀកបំពាក់សម្ភារៈបរិក្ខាដល់ប្រជាការពារឃុំអស់ថវិកា ៥.៨៤០.០០០រៀល(ថវិកាឃុំ)។

- បានធ្វើការតម្លើងអំពូលបំភ្លឺសាធារណៈនៅភូមិពង្រ ចំនួន ៣០អំពូល និងភូមិផ្លាំង ចំនួន ៥០ អំពូល សរុបចំនួន ៨០ អំពូល ដែលជាការជួយឧបត្ថម្ភពីប្រជាពលរដ្ឋក្នុងភូមិ និងសប្បុរសជនក្នុង និងក្រៅឃុំ ។

- ផ្នែកកសិកម្ម ៖

- ការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០២០ ផែនការសរុប ៣៦២០ហិកតា ក្នុងនោះភ្ជួរដោយគោយន្តចំនួន ៣៦២០ហិកតា ដោយព្រោះស្រូវស្រាលសរុប ៨០០ហិកតា ស្រូវ កណ្តាល ១៦២០ហិកតា ស្រូវធ្ងន់ ៥០០ហិកតា ទទួលបានទិន្នផល ២,៥តោនក្នុងមួយហិកតា
- ដំណាំរួមផ្សំអនុវត្តបាន ១៧ហិកតា ក្នុងនោះពោត ១ហិកតា ដំឡូងមី ២ហិកតា ដំឡូងជ្វា ១ហិកតា និងបន្លែ គ្រប់មុខ ១៣ហិកតា។
- កសិដ្ឋានចិញ្ចឹមមាន់ ២ កន្លែង
- កសិករ ធ្វើស្រែ ៣៩៧០ ហិកតា

- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ៖

រដ្ឋបាលឃុំព្រៃផ្ដៅកបានកសាងផ្លូវ ចំនួន ១១ខ្សែ ដែលមានប្រវែងសរុប ២៧.៦៨២ម ដោយបានដាក់លូរំដោះទឹក ៧កន្លែង ព្រមទាំងបានសាងសង់សាលាបឋមសិក្សា និងបណ្ណាល័យ ២ខ្នង ស្មើនឹង ៤ បន្ទប់ ដោយប្រើប្រាស់ថវិកាសរុបចំនួន ៧២៤.៤៣២.៧៨៨រៀល ក្នុងនោះ៖

- ផ្លូវបេតុង២ ខ្សែ ប្រវែង ២.៣៥៨ម (កសាងដោយមន្ទីរអភិវឌ្ឍន៍ជនបទ គម្រោងកាត់បន្ថយហានីភ័យ គ្រោះមហន្តរាយ មូលនិធិឃុំ និងសប្បុរសជន)
- ផ្លូវក្រាលគ្រួសក្រហម ៩ខ្សែ ប្រវែង ២៥.៣២៤ម (កសាងដោយមន្ទីរអភិវឌ្ឍន៍ជនបទ គម្រោងឈាក និងមូលនិធិឃុំ)
- ដាក់លូរំដោះទឹក ចំនួន ៧កន្លែង (កសាងដោយគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ( ឈាក) និងមូលនិធិឃុំ)
- សាងសង់សាលាបឋមប្រដាក់ ១ខ្នង ៣បន្ទប់ ( ឧបត្ថម្ភ ដោយសប្បុរសជន )
- សាងសង់ទីចាត់ការ ១ខ្នង ១បន្ទប់ នៅសាលាបឋមប្រាសាទ ( ឧបត្ថម្ភ ដោយអង្គការ-ទស្សនៈពិភពលោក និងសប្បុរសជន )
- សាងសង់អាគារអប់សីលធម៌ ១ខ្នង ( ឧបត្ថម្ភ ដោយសប្បុរសជន)
- សាងសង់ក្លឹបកុមារបានចំនួន៥កន្លែង( កសាងដោយអង្គការទស្សនៈពិភពលោក និងសហគមន៍ )
- សាងសង់អាគារសម្រាប់រង់ចាំស្ត្រីមកសម្រាលកូន និងកន្លែងសម្រាប់បុគ្គលិកសម្រាក ( កសាងដោយអង្គការទស្សនៈពិភពលោក និងសប្បុរសជន )

- ផ្នែកសង្គមកិច្ច៖ គាំទ្រសេវាសង្គម( គកនក ) ចំណាយថវិកាអស់ ៦២,៣២៨,០០០៛ ដោយ៖
  - ជួយសិស្សក្រីក្រ រៀននៅបឋមសិក្សាចំនួន ៤០ នាក់ ( សំលៀកបំពាក់ សិស្ស, កាបូប, សំភារៈសិក្សាសម្រាប់រយៈពេល ១ ឆ្នាំ )
  - ជួយកង់ដល់សិស្សក្រីក្រ រៀននៅបឋមសិក្សាចំនួន ២៥ នាក់
  - គ្រួសារមានផ្ទុកមេរោគ អេដស៍ ចំនួន ២៧ នាក់
  - ឧបត្ថម្ភសម្ភារបង្គន់អនាម័យដល់គ្រួសារក្រីក្រ ២៧៤ គ្រួសារ
  - ផ្តល់ប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋក្រីក្រ បានចំនួន ៣១៩ ប័ណ្ណ ( ក្រ១=៩២, ក្រ២= ២២៧ )
  - ផ្តល់កាតវីង ក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដល់ស្រ្តីក្រីក្រមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ឆ្នាំ បានចំនួន ១០០ នាក់។
  - ផ្តល់ពាង១៩៩ និងធុងចម្រោះទឹក ចំនួន ១៩៩ធុង ដល់គ្រួសារក្រីក្រ( ឧបត្ថម្ភ ដោយ អង្គការទស្សនៈពិភពលោក )
  - បង្កើតក្រុមសន្សំដល់គ្រួសរក្រីក្រចំនួន២១ក្រុម និងក្រុមផលិតមានចំនួន១០ក្រុម ដែលជាគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ ( លាភ )
  - ផ្តល់ផ្ទះជូនគ្រួសារក្រីក្រចំនួន១៣គ្រួសារអស់ប្រាក់ចំនួន ១៥០.៨០០.០០០៛ ឧបត្ថម្ភដោយអង្គការលំនៅដ្ឋាន
  - បញ្ជូនសិស្សចូលរួមរៀនសូត្រវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលជាគម្រោង លើកកម្ពស់ជីវភាពប្រជាជនក្រីក្រ ចំនួន ០៥ នាក់ ស្រី ០១ នាក់ ។
- សកម្មភាពមនុស្សធម៌៖ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ បានខិតខំ យកចិត្តទុកដាក់ យកអស់កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី និង ថវិកា ចុះសួរសុខទុក្ខ ស្វែងយល់ពីបញ្ហា តម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ ជួយឧបត្ថម្ភគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រជួបការលំបាក ជនចាស់ជរា ស្រ្តី មេម៉ាយ ស្រ្តីមានផ្ទៃពោះ ជនពិការ គ្រួសារសព ដូចខាងក្រោម៖
  - គ្រួសារដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩ ចំនួន ៣១៩គ្រួសារ ដោយប្រើប្រាស់ ៖ អង្ករ ,មី , ត្រីខ ,ទឹកត្រី ,ទឹកស៊ីអ៊ីវ សាប៊ូ ,ជេលលាងដៃ , អាល់កុល , ទឹកសុទ្ធ ម៉ាស់ ថ្នាំផុសធ្មេញ,អំបិល,ប៊ីចេង ,ថវិកា និង ចាក់ផ្សាយសារណែនាំរបស់ក្រសួងសុខាភិបាល តាមមេក្រូចល័ត គ្រប់ខ្នងផ្ទះ ចំណាយថវិកាអស់សរុប ១៥៤.៨០៨.០០០៛ ។
  - ប្រជាពលរដ្ឋដែលរងគ្រោះនិង ប៉ះពាល់ដោយសារទឹកជំនន់ ចំនួន៤០៩ គ្រួសារ ដោយប្រើប្រាស់ អង្ករ, មី, ទឹកសុទ្ធ,ត្រីខ, ទឹកស៊ីអ៊ីវ, ទឹកត្រី,អំបិល , ប្រេងឆា ម្សៅសាប៊ូ

,ប្រេងឆា ,ស្កសរ ,ទឹកដោះគោឆៅ, ក្អួយ,មុង , ស្រូវពូជ ( ឧបត្ថម្ភ ដោយអង្គារទស្សនៈពិភពលោក រដ្ឋបាលស្រុក អង្គការជីវិតនៅកម្ពុជា អង្គការជីវីវើល និងមូលនិធិឃុំ ) ។

- ជួយកង្ការនៅសាលាអនុវិទ្យាល័យហ៊ុនសែនព្រៃជ្រូក និងសាលាបឋមសិក្សាចំនួន ៨.៨០០.០០០៛( ឧបត្ថម្ភ ដោយសប្បុរសជន )

III. ទិសដៅការងារបន្ត

❖ ក្រុមប្រឹក្សាខេត្ត

- បន្តពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ផ្សព្វផ្សាយលក្ខណៈសម្បត្តិ ០៩យ៉ាង នៃភូមិ ឃុំ មានសុវត្ថិភាព ជំរុញចលនាប្រជាជនចូលរួម និងកសាងកម្លាំងប្រជាការពារ សាងសង់ប៉ុស្តិ៍ប្រជាការពារ សម្រាប់ចូលរួមសហប្រតិបត្តិការបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ។
- គ្រប់មន្ទីរ អង្គភាពត្រូវរួមសហការឱ្យបានកាន់តែសកម្ម និងមានប្រសិទ្ធភាព និងចាត់វិធានការបើកកិច្ចប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសគ្រប់ប្រភេទរួមមាន បទល្មើសផ្លូវភេទ ការជួញដូរស្ត្រី និងកុមារ គ្រឿងញៀន ល្បែងស៊ីសង បទល្មើសបច្ចេកវិទ្យា បទល្មើសសេដ្ឋកិច្ច ពិសេសផលិតផលក្លែងក្លាយមានសារធាតុគីមីហាមឃាត់គ្រប់ប្រភេទ និងឱសថក្លែងក្លាយ។
- ពង្រីកសក្តានុពលទេសចរណ៍ ដោយពង្រីកតំបន់ទេសចរណ៍ធម្មជាតិ និងតំបន់កែច្នៃក្រៅពី ប្រាសាទ និងសេវាកម្មទេសចរណ៍ អភិវឌ្ឍធនធានមនុស្សផ្នែកជំនាញវិជ្ជាជីវៈទេសចរណ៍លើការងារបដិសណ្ឋារកិច្ច សេវាកកម្មដឹកជញ្ជូន និងសេវាមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងរៀបចំផែនការអភិវឌ្ឍទេសចណ៍ទៅតាមតំបន់គោលដៅទេសចរណ៍ក្នុងក្រុង និងតាមបណ្តាស្រុក។ ជាមួយគ្នានោះ ខេត្តនឹងអនុវត្តសកម្មភាពនានាឆ្លើយតបទៅនឹងស្ថានភាព នៃការធ្លាក់ចុះភ្ញៀវទេសចរស្របតាមវិធានការនានារបស់រាជរដ្ឋាភិបាលការស្តារហេដ្ឋារចនាផ្លូវថ្នល់ និង ការកែលម្អសោភ័ណ្ឌភាពក្នុងក្រុងប្រកបដោយភាពទាក់ទាញ និង ទីក្រុងឆ្លាតវៃ។
- បន្តជំរុញការដាំដុះ ផ្សព្វផ្សាយបច្ចេកទេសកសិកម្មទំនើប បង្កើនផលិតផលកសិកម្មតាមកិច្ចសន្យា ពង្រីកឱ្យមានផលិតផលសុវត្ថិភាពនៅលើទីផ្សារ ការចិញ្ចឹមសត្វ វារីវប្បកម្ម រៀបចំពិព័រណ៌ផលិតផល គាំទ្រការកែច្នៃ វេចខ្ចប់ និងទីផ្សារ ក្នុងន័យបង្កើត ប្រាក់ចំណូលគ្រួសារ កាត់បន្ថយចំណាកស្រុក ការនាំចូល និងបំពេញតម្រូវការក្នុងស្រុក និងការនាំចេញ។

- គណៈកម្មាការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយដើម្បីផ្តល់នូវនិមិត្តសញ្ញាភូមិមួយផលិតផលមួយក្នុងការជ្រើសរើសផលិតផល ដែលមានសក្តានុពល និងល្អបំផុតប្រចាំខេត្ត។
- ពន្លឿនការចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធតាមក្រុង ស្រុក ដើម្បីផ្តល់ប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋឱ្យបានចប់តាមផែនការឆ្នាំ២០២១។
- ស្នើសុំការគាំទ្របច្ចេកទេស ក្នុងការរៀបចំប្លង់គោលដីធ្លីស្រុក តាមបណ្តោយផ្លូវជាតិលេខ ៦។ ដោយឡែកស្រុកដទៃទៀត ត្រូវយកចិត្តទុកដាក់រៀបចំទីប្រជុំជនស្រុក ឃុំ ឱ្យមានរបៀបរៀបរយ និងប្រកបទៅដោយទស្សនៈវិស័យទីប្រជុំជន។
- អប់រំ ផ្សព្វផ្សាយ ពង្រឹងការទប់ស្កាត់ និងចាត់វិធានការតាមផ្លូវច្បាប់ចំពោះការបំផ្លាញធនធានធម្មជាតិ និងទន្ទ្រានកាន់កាប់ដីព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ព្រៃសហគមន៍ ដែនអភិរក្ស និងរបៀងជីវៈចម្រុះ លើកផែនការការងារសម្រាប់ការបោះបង្គោលព្រំប្រទល់ និងលើកស្លាកសញ្ញាហាមឃាត់ ឬសម្គាល់តំបន់ទាំងនោះ។
- ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក លើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងគ្រប់គ្រងប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនក្នុងការគ្រប់គ្រងសំរាម។
- ពង្រឹងការផ្តល់សេវារដ្ឋបាលតាមរយៈច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក ឱ្យបានឆាប់រហ័ស ធានាបានតម្លាភាព និងដោះស្រាយ ឬលើកសំណូមពរដោះស្រាយចំពោះ សេវាមានលក្ខណៈស្មុគស្មាញ។

❖ ឃុំព្រៃជ្រូក នៃស្រុកពួក

- បន្តការយកចិត្តទុកដាក់បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋអោយបានឆាប់រហ័ស ប្រកបដោយបរិយាប័ន្ន ។
- បន្តខិតខំពង្រឹងកំលាំងនគរបាលប៉ុស្តិ៍ និង ប្រជាការពារ ដើម្បីអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព អោយបានល្អ ។
- ផ្សព្វផ្សាយ និងផ្តល់ឱកាស ឱ្យប្រជាពលរដ្ឋ យល់ដឹង អំពីច្បាប់ និង លិខិតបទដ្ឋាននានា គោលការណ៍ណែនាំ បញ្ជ្រាបចំណេះដឹង ក្នុងការបង្កើតមុខរបរខ្នាតតូច ជូនដល់ប្រជាពលរដ្ឋ ។
- លើកកម្ពស់ការយល់ដឹងពី ផែនការគណនេយ្យភាពសង្គម ។
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំ រំកិល និងអនុវត្តគម្រោងមូលនិធិឃុំ ឱ្យបានទាន់ពេលវេលា ។

- បន្តផ្សព្វផ្សាយពីវិធានការការពារ ទប់ស្កាត់ជំងឺ ឆ្លងនានា ជាពិសេសជម្ងឺកូវីដ ១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល និងរបៀបរស់នៅស្អាត ហូបស្អាត និងការធ្វើអនាម័យបរិស្ថាន ។
- ផ្សព្វផ្សាយ និង ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះវេចខ្ចប់ទុកដាក់ សម្រាម និង កាកសំណល់ឱ្យបានត្រឹមត្រូវ ។
- ផ្សព្វផ្សាយ និង ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះប្រុងប្រយ័ត្នមិនឲ្យចាញ់បោកជនទុច្ចរិត ។
- ផ្សព្វផ្សាយ និង ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះប្រុងប្រយ័ត្ន និងចេះទុកដាក់ទ្រព្យសម្បត្តិ ។
- ខិតខំគៀងគរដៃគូ អ្នកវិនិយោគ សប្បុរសជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុង ។ល។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១